អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens



ថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០១០

# សេចក្តីប្រកាសព័ត៌មាន

## អគ្គលេខធិការអង្គការសហប្រជាជាតិ លោក បាន គីមូន កោតសរសើរការវិវត្តរបស់ អ.វ.ត.ក.

ថ្ងៃនេះ អគ្គលេខធិការអង្គការសហប្រជាជាតិ លោក បាន គីមូន បានធ្វើដំណើរទស្សនកិច្ចមកកាន់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក.) ដែលជាផ្នែកមួយនៃទស្សនកិច្ចផ្លូវការរបស់លោកមកកាន់ប្រទេសកម្ពុជា។ លោកអគ្គលេធិការត្រូវបានរួមដំណើរជាមួយដោយ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី សុខ អាន ហើយលោកបានជួបប្រជុំជាមួយមន្ត្រីនិងបុគ្គលិក អ.វ.ត.ក. នៅសាលសវនាការ អ.វ.ត.ក.។

នៅក្នុងសុន្ទរកថាខ្លីរបស់លោក លោកអគ្គលេខាធិការបានសំដែងការកោតសរសើរដល់កិច្ចការរបស់តុលាការ ហើយបានសង្កត់បញ្ជាក់ថា សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿងលេខ ០០១ ប្រឆាំងនឹង កាំង ហ្គេចអ៊ាវ ហៅ ឌុច បានបង្ហាញពីសមត្ថភាពរបស់ អ.វ.ត.ក. ក្នុងការអនុវត្តនីតិវិធីព្រហ្មទណ្ឌស្មុគស្មាញពាក់ព័ន្ធនឹងបទឧក្រិដ្ឋអន្តរជាតិ ដោយអនុលោមតាមបទដ្ឋានអន្តរជាតិ។ លោកអគ្គលេខាធិការមានប្រសាសន៍ថា ចំនួនប្រជាជនដែលបានចូលរួមតាមដានសវនាការនៅក្នុងសំណុំរឿង ០០១ ជាង ៣១០០០ នាក់ ជាចំនួនមិនដែលមានពីមុនមក ហើយបានបង្ហាញយ៉ាងជាក់ច្បាស់ពីចំណាប់អារម្មណ៍របស់ប្រជាជនកម្ពុជា និងការទាមទាររបស់ពួកគេក្នុងការនាំមកនូវអត្ថន័យនៃការបង្រួបបង្រួមនិងបិទទំព័រដ៏គួរឲ្យរន្ធត់នៅក្នុងប្រវត្តិសាស្ត្ររបស់ពួកគេ។

លោកអគ្គលេខាធិការបានបង្ហាញពីកិច្ចសហប្រតិបត្តិការជិតស្និទ្ធរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ក្នុងការគាំទ្រដំណើរការរបស់ អ.វ.ត.ក.។ លោកក៏បានបញ្ជាក់សារជាថ្មីពីការប្តេជ្ញាចិត្តរបស់លោកផ្ទាល់ ដើម្បីធានាថា អ.វ.ត.ក. នឹងបញ្ចប់អាណត្តិរបស់ខ្លួនប្រកបដោយជោគជ័យ។